# លោកស្រី ចក់ សុភាព៖ ការដាក់ទោសលោក កឹម សុខា ធ្វើឲ្យអ្នកសង្កេតការណ៍មានការខកចិត្តខ្លាំង។

សាលាដំបូងរាជធានីភ្នំពេញនៅព្រឹកថ្ងៃសុក្រនេះ បានប្រកាសសាលក្រមសម្រេចផ្តន្ទាទោសលោក កឹម សុខា ដាក់ពន្ធនាគារចំនួន២៧ ឆ្នាំពីបទ«សន្ទិដ្ឋិភាពជាមួយបរទេស» ព្រមទាំងដកហូតសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយជាស្ថាពរទៀតផង។ លោកស្រី ចក់ សុភាព នាយិការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានមើលឃើញថាសាលក្រមកាត់ទោសលោក កឹម សុខា ឲ្យជាប់ទោសរយៈពេល២៧ឆ្នាំ ធ្វើឲ្យមានការខកចិត្ត សម្រាប់អ្នកសង្កេតការណ៍ ហើយក៏គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលនោះទេ។ តាមលោកស្រី ចក់ សុភាព ករណីដាក់ទោសលោក កឹម សុខា គឺដូចអ្វីដែលលោកស្រីបានគិតទុកជាមុនថានឹងចេញតាមសេណារីយ៉ូបែបនេះ។



លោកស្រី ចក់ សុភាព នាយិការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា  Internet

---

## លោក ស្រ៊ុន ស្រ៊ិនៈករណីវាយក្បាលខ្ញុំរបួសជាការបំបាក់ស្មារតី តែខ្ញុំមិនចុះចាញ់

លោក ស្រ៊ុន ស្រ៊ិន ត្រូវបានជនល្មើសវាយបែកក្បាលនៅថ្ងៃទី៣១ធ្នូ២០២៣ ខណៈលោកនិងសហការីម្នាក់ទៀតកំពុងផ្សាយផ្ទាល់ពីខ្លឹមសារនៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសទៅកាន់ពលករខ្មែរនៅប្រទេសថៃ។ ក្នុងបទសម្ភាសជាមួយវិទ្យុបារាំងអន្តរជាតិ RFI ថ្ងៃទី១ មករា ២០២៤ លោក ស្រ៊ុន ស្រ៊ិន អះអាងថា ជនល្មើសមានគ្នា៣នាក់ដោយពីរនាក់ជាជនដៃដល់ វាយលើរូបលោក និងកញ្ញា សោភា។ តាមសកម្មជនកិច្ចព្រមព្រៀងក្រុងប៉ារីសរូបនេះ ការវាយប្រហារមកលើរូបលោកជាការបំបាក់ស្មារតីមិនឲ្យបន្តផ្សាយកិច្ចព្រមព្រៀងក្រុង ប៉ារីស ២៣ តុលា តែលោកអះអាងថា លោកនឹងមិនចុះចាញ់ឡើយ។ គួរ រម្លឹក ថា លោក ស្រ៊ុន ស្រ៊ិន ធ្លាប់ត្រូវបានសមត្ថកិច្ចថៃប៉ុនប៉ងចាប់ខ្លួនក្រោមការអះអាងថា ធ្វើឡើងទៅតាមពាក្យបណ្ដឹងរបស់រដ្ឋាភិបាលកម្ពុជា។

## លោក គីមសួរ ភីរិទ្ធៈ ការតវ៉ាឲ្យដកប្រធានបក្សភ្លើងទៀន គឺមានអ្នកនៅពីក្រោយ

ការទាមទារឲ្យដកប្រធាន និងអគ្គលេខាធិការគណបក្សភ្លើងទៀនចេញមានន័យស្មើនឹងរុញឲ្យគណបក្សនេះរលាយ។ នេះគឺជាការឆ្លើយតបរបស់អតីតអ្នកនាំពាក្យគណបក្សភ្លើងទៀនចំពោះការតវ៉ានៅព្រឹកនេះ ខណៈអ្នកតវ៉ាទាមទារឲ្យទម្លាក់លោក ទាវ វណ្ណុល ពីប្រធានបក្ស និងលោក លី សុធារ៉ាយុត្តិ ពីអគ្គលេខាធិការបក្ស។ បើតាម លោក គីមសួរ ភីរិទ្ធ ការតវ៉ាបែបនេះ គឺមានអ្នកនៅពីក្រោយ

។ ក្នុងបទសម្ភាសជាមួយវិទ្យុបារាំងអន្តរជាតិRFI លោក គីមសួរ ភីរិទ្ធ អះអាងថា អ្នកដែលចេញតវ៉ានោះមិនមែនជាក្រុមប្រឹក្សារបស់គណបក្សភ្លើងទៀនទៀតទេ ពីព្រោះពួកគេបានទៅចូលរួមជាមួយគណបក្សកម្លាំងជាតិ និងចូលជាមួយគណបក្សផ្សេងតាំងពីក្រោយបោះឆ្នោត២៣កក្កដា។

## តេជគុណ ទេព ភឿន៖ វត្តពោធិលង្កានឹងក្លាយស្រែបុណ្យសម្រាប់ពលរដ្ឋ ក្រោយបើកឡើងវិញ

វត្តពោធិលង្កា នៅខេត្តសៀមរាប ដែលបានបិទទ្វារដោយវិវាទផ្ទៃក្នុងកាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ បានបើកដំណើរការឡើងវិញហើយ។ ក្នុងបទសម្ភាសជាមួយវិទ្យុបារាំងអន្តរជាតិនៅថ្ងៃទី១៥ខែធ្នូនេះ បវរវិជ្ជា ទេព ភឿន ព្រះវិន័យធមិខេត្ត និងជាអ្នកនាំពាក្យសាលាគណខេត្តសៀមរាប មានសង្ឃដិកាថា ទោះបីវត្តធិលង្កានេះបានដំណើរការហើយក្តី ក៏ប៉ុន្តែរចនាសម្ព័ន្ធគ្រប់គ្រង ក៏ដូចជាការសម្របសម្រួល និងការរៀបចំរបៀបរៀបរយមួយចំនួននៅតែមិនទាន់សម្រេចនៅឡើយទេ។ តាមបវរវិជ្ជា ទេព ភឿន ក្នុងចំណោមព្រះសង្ឃទាំងអស់១៤០អង្ឃ គឺមានព្រះសង្ឃជាង២០អង្គ ដែលត្រូវបានអនុញ្ញាតិឱ្យត្រលប់ទៅគង់នៅវត្តពោធិលង្កាវិញ ។ ចំណែកព្រះសង្ឃដែលនៅសេសសល់នឹងត្រូវគណៈសង្ឃពិនិត្យមើលនៅពេលក្រោយ។ ព្រះបវរវិជ្ជា ទេព ភឿន មានជំនឿថា វត្តពោធិលង្កានឹងក្លាយជាទីតាំងផ្តល់ការអប់រំធមិអាថិសិក្ខាវិន័យពិត និងជាស្រែបុណ្យសម្រាប់ពលរដ្ឋដើម្បីបំពេញសទ្ធាជ្រះថ្លា។

## លោក ឡុង កុសល ចង់ឃើញព្រឹត្តការណ៍រឹពួកគុណអង្គរទាក់ទាញភ្ញៀវទេសចរដូចអង្គរសង្ក្រាន្ត

ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ ជាខួប៣១ឆ្នាំនៃការដាក់រមណីយដ្ឋានអង្គរទៅក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ។ ដើម្បីអបអរសាទរទិវានេះ ក្រសួងវប្បធម៌ តាមរយៈអាជ្ញាធរជាតិអប្សរាកំពុងរៀបចំធ្វើព្រឹត្តិការណ៍រំឭកគុណអង្គរនៅខេត្តសៀមរាប រយៈពេល១០ថ្ងៃ។ កម្មវត្ថុនៃការរៀបចំព្រឹត្តិការណ៍មួយនេះ គឺដើម្បីបង្ហាញពីការដឹងគុណដល់បុព្វបុរសខ្មែរដែលបានកសាង និងថែរក្សាប្រាសាទទាំងអស់នៅក្នុងរមណីយដ្ឋានអង្គរដោយបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ជាតិមាតុភូមិតាំងពីដើមរហូតមកដល់សព្វថ្ងៃ។ នៅក្នុងបទសម្ភាសជាមួយវិទ្យុបារាំងអន្តរជាតិនាថ្ងៃទី១៣ ធ្នូ លោក ឡុង កុសល អគ្គនាយករង និងជាអ្នកនាំពាក្យអាជ្ញាធរជាតិអប្សរាចង់ឃើញព្រឹត្តិការណ៍រំឭកគុណអង្គរទាក់ទាញភ្ញៀវទេសចរដូចព្រឹត្តិការណ៍អង្គរសង្ក្រាន្តដែរ។

## វេជ្ជបណ្ឌិត Patrick Jouhaud ចង់ឱ្យមានអ្នកជំនាញផ្នែកលំនឹងសរីរាង្គនៅកម្ពុជា

នៅឆ្នាំ២០២៣នេះ បេសកកម្មផ្តល់ការថែទាំផ្នែកលំនឹងសរីរាង្គ (osteopathy)ដែលជាការព្យាបាលជំងឺដោយមិនប្រើប្រាស់ថ្នាំពេទ្យរបស់អង្គការហត្ថាវេជ្ជសាស្ត្រ បានជួយដល់កុមារកម្ពុជាប្រមាណ ២ពាន់នាក់រស់នៅក្នុងមណ្ឌលកុមារកំព្រាចំនួន២១មណ្ឌលស្ថាប័ន។ ទន្ទឹមគ្នានេះដែរ អង្គការហត្ថាវេជ្ជសាស្ត្រក៏មានបេសកកម្ម បង្រៀនចំណេះដឹងផ្នែកលំនឹងសរីរាង្គ (osteopathy)នេះ ដល់អ្នកជំនាញវិជ្ជាជីវៈសុខាភិបាលកម្ពុជានៅតាមមន្ទីរពេទ្យរដ្ឋធំៗផងដែរ។ នៅក្នុងបទសម្ភាសជាមួយវិទ្យុបារាំង លោកវេជ្ជបណ្ឌិត Patrick Jouhaud អនុប្រធានអង្គការហត្ថាវេជ្ជសាស្ត្រ ប្រាថ្នាចង់ឱ្យប្រទេសកម្ពុជាមាន

អ្នកជំនាញផ្នែកលំនឹងសរីរាង្គមន្ទីរពេទ្យរដ្ឋឱ្យបានឆាប់ ខណៈបច្ចុប្បន្នអ្នកជំនាញវេជ្ជសាស្ត្រនៅកម្ពុជាមានត្រឹម២ឬ៣នាក់ប៉ុណ្ណោះដែលយល់ដឹងផ្នែកលំនឹងសរីរាង្គ (osteopathy)នេះ៕